OECD Development Pathways

# ទំនាក់ទំនងរវាង គោលនយោបាយសាធារណៈ ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍ នៅកម្ពុជា



CAMBODIA

OECD DEVELOPMENT CENTRE

បោះពុម្ពផ្សាយដោយ OECD និង វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ជាភាសាអង់គ្លេស មានចំណងជើងថា៖

Interrelations between Public Policies, Migration and Development in Cambodia, “Chapter 1: Overview and policy recommendations in Cambodia”.

គុណភាពការបកប្រែ និង ការជាប់ទាក់ទិននានាជាមួយអត្ថបទខ្លឹមសារជាភាសាដើម ជាការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ។ បើសិនមានការប្លែកគ្នារវាងអត្ថបទដើម និងអត្ថបទបកប្រែ ត្រូវយកអត្ថបទដើម ជាបានការ។

© OECD/Cambodia Development Resource Institute 2017

# ជំពូក ១
# ទិដ្ឋភាពទូទៅ និង ការផ្ដល់មតិផ្នែកគោលនយោបាយនៅកម្ពុជា

*កម្ពុជាកំពុងបាត់បង់ឱកាសទាញយកប្រយោជន៍ពីអន្តោប្រវេសន៍យ៉ាងខ្ពស់នៃការធ្វើចំណាកស្រុក ដើម្បីជំរុញការអភិវឌ្ឍប្រទេស។ គម្រោងស្ដីពី ទំនាក់ទំនងចុះឡើងរវាងគោលនយោបាយសាធារណៈ ចំណាកស្រុក និង ការអភិវឌ្ឍ (IPPMD) បានអនុវត្តនៅប្រទេសកម្ពុជា ចាប់ពីឆ្នាំ២០១៣ ដល់ ២០១៧ ដើម្បីស្រាវជ្រាវតាមការវិភាគទាំងតាមបែបបរិមាណ និងបែបគុណភាព ពី ទំនាក់ទំនងទៅវិញទៅមករវាងចំណាកស្រុក និងគោលនយោបាយសាធារណៈ ក្នុង ៤ វិស័យសំខាន់ៗ គឺ ទីផ្សារពលកម្ម កសិកម្ម ការអប់រំ និង វិនិយោគនិងសេវាហិរញ្ញវត្ថុ។ ជំពូកនេះ បូកសរុបត្រួសៗពី លទ្ធផលរកឃើញក្នុងគម្រោងនេះ គូសបញ្ជាក់ពីសក្ដានុពលនៃចំណាកស្រុកដែលមានទិដ្ឋភាពជាច្រើន (ចំណាកស្រុក បញ្ញើមកផ្ទះ ចំណាកស្រុកត្រឡប់មកវិញ) ដើម្បីជំរុញការអភិវឌ្ឍ និង ធ្វើការវិភាគលើគោលនយោបាយតាមវិស័យនានានៅកម្ពុជាដែលអនុញ្ញាតឲ្យមានចំណាកស្រុក។*

ចំណាកស្រុកក្រៅប្រទេស អាចក្លាយជាកត្តាកំណត់ដ៏សំខាន់មួយ សម្រាប់ការអភិវឌ្ឍនៅកម្ពុជា ដោយសារតែមានផលប៉ះពាល់កាន់តែច្រើនខាងផ្នែកសង្គម និងសេដ្ឋកិច្ច។ ទោះបីកម្ពុជាមានកំណើនសេដ្ឋកិច្ចនឹងនរប្រមាណ ៧% ក្នុងមួយឆ្នាំ តាំងពីឆ្នាំ២០១០ មកក្ដី ក៏តម្រូវការក្នុងទីផ្សារពលកម្មមិនមានគ្រប់គ្រាន់ដើម្បីស្រូបយកកំណើនពលករនេះទេ ជាពិសេសក្នុងចំណោមប្រជាជនវ័យក្មេង។ ភាពក្រីក្រទៀតសោត ក៏នៅមានកម្រិតខ្ពស់គួរកត់សំគាល់ ថ្វីបើមានសញ្ញាបង្ហាញថា វាកំពុងធ្លាក់ចុះក្ដី។ ក្នុងស្ថានភាពនេះ គ្រួសារជាច្រើនបានជ្រើសយកចំណាកស្រុកធ្វើជា យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់កម្រិតជីវភាពរបស់ខ្លួន។ សំណួរសំខាន់នៅពេលនេះ គឺ តើត្រូវបង្កើតបរិយាកាសគោលនយោបាយដែលមានលក្ខណៈអំណោយផលបែបណា ដើម្បីអាចទាញយកអត្ថប្រយោជន៍បានច្រើនបំផុតពីចំណាកស្រុក ដើម្បីជំរុញការអភិវឌ្ឍប្រទេសកម្ពុជា។

របាយការណ៍នេះសំដៅផ្ដល់ជូនអ្នកកសាងគោលនយោបាយនូវ ភស្តុតាងជាក់ស្ដែងពីឥទ្ធិពលនៃចំណាកស្រុក នៅក្នុងគោលនយោបាយផ្សេងៗដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងឥទ្ធិពលទៅ លើចំណាកស្រុកនៃ គោលនយោបាយសាធារណៈមិនមែនស្ដីពីចំណាកស្រុក (ប្រអប់១.១)។ ជំពូកនេះបង្ហាញត្រួសៗពីលទ្ធផលរកឃើញ និងមតិយោបល់មួយចំនួនផ្នែកគោលនយោបាយ ដើម្បីដាក់បញ្ចូលបញ្ហាទំនាក់ទំនងចុះឡើងរវាងចំណាកស្រុក នឹងគោលនយោបាយសាធារណៈ ទៅក្នុងការរចនារៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍។


© OECD/Cambodia Development Resource Institute 2017

ប្រអប់១.១៖ តើគម្រោង IPPMD ជាអ្វី?

នៅខែមករា ២០១៣ មជ្ឈមណ្ឌលអភិវឌ្ឍន៍នៃ អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) បានចាប់ផ្តើមគម្រោងមួយស្តីពី *ទំនាក់ទំនងចុះឡើងរវាងគោលនយោបាយសាធារណៈ ចំណាកស្រុក នឹងការអភិវឌ្ឍ៖ ករណីសិក្សា និងការផ្តល់មតិផ្នែកគោលនយោបាយ* (IPPMD)។ គម្រោងនេះទទួលបានមូលនិធិមួយភាគពី កម្មវិធីរបស់សហភាពអឺរ៉ុបស្តីពីចំណាកស្រុក និងការជ្រកកោន និងអនុវត្តក្នុង ១០ ប្រទេសមានចំណូលទាប និងមធ្យម ពីឆ្នាំ២០១៣ ដល់ ២០១៧ ដើម្បីស្វែងរកភស្តុតាងជូនអ្នកកសាងគោលនយោបាយអំពី សារៈសំខាន់នៃការដាក់បញ្ចូលបញ្ហាចំណាកស្រុកទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការបង្កើនភាពរលូនគ្នារវាងគោលនយោបាយតាមវិស័យផ្សេងៗ។ គម្រោងនេះបានជ្រើសរើសប្រទេសកំពុងអភិវឌ្ឍន៍ខុសៗដែលតំណាងបានយ៉ាងល្អនូវប្រទេសនានា ដូចជា អាមេនី បួគីណាហ្វាសូ កម្ពុជា កូស្តារីកា កូតឌីវ័រ សាធារណរដ្ឋដូមីនីក ហ្សកហ្ស៊ី ហៃទី ម៉ារ៉ុក និងហ្វីលីពីន។

ភស្តុតាងមានច្រើនមែនហើយដែលបង្ហាញពីឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមាននៃចំណាកស្រុកទៅលើការអភិវឌ្ឍ ប៉ុន្តែហេតុផលដែលអ្នកកសាងគោលនយោបាយគួរដាក់បញ្ចូល បញ្ហាចំណាកស្រុកទៅក្នុងផែនការអភិវឌ្ឍ គឺនៅខ្វះខាតមូលដ្ឋានជាក់ស្តែង។ គម្រោង IPPMD ព្យាយាមបំពេញចន្លោះខ្វះខាតនេះ ដោយផ្តល់នូវភស្តុតាងគួរទុកចិត្តបាន មិនត្រឹមតែលើការចូលរួមចំណែកនៃចំណាកស្រុកដល់ការអភិវឌ្ឍនោះទេ ប៉ុន្តែថែមទាំងបង្ហាញពីបែបបទដែល ការចូលរួមចំណែកនេះអាចពង្រឹងបន្ថែមបានតាមរយៈគោលនយោបាយតាមវិស័យផ្សេងៗ។ ដើម្បីសម្រេចកិច្ចការនេះ អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) បានកសាងក្របខ័ណ្ឌគោលគំនិតមួយ ដើម្បីស្រាវជ្រាវពី ចំណងទាក់ទងរវាង ទិដ្ឋភាពទាំង ៤ នៃការធ្វើចំណាកស្រុក (ចំណាកស្រុក បញ្ញើមកផ្ទះ ចំណាកស្រុកត្រឡប់វិញ ចំណាកស្រុកចូល) និង គោលនយោបាយតាមវិស័យសំខាន់ៗទាំង ៥ គឺ ទីផ្សារពលកម្ម កសិកម្ម ការអប់រំ វិនិយោគ និងសេវាហិរញ្ញវត្ថុ និង ការគាំពារសង្គមនិងសុខាភិបាល (រូបភាព១.១)។

ក្របខ័ណ្ឌគោលគំនិតនេះ ក៏បានតភ្ជាប់គោលនយោបាយតាមវិស័យទាំង៥ នេះ ទៅនឹងលទ្ធផលផ្សេងៗនៃការធ្វើចំណាកស្រុកដែរ (តារាង១.១)។

រូបភាព១.១៖ ចំណាកស្រុក និងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ៖ ទំនាក់ទំនងទៅវិញទៅមក




 © OECD/Cambodia Development Resource Institute 2017

មានភស្តុតាងជាច្រើនបង្ហាញពី ផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាន នៃចំណាកស្រុកទៅលើការអភិវឌ្ឍ ប៉ុន្តែហេតុផលដែលអ្នកកសាងគោលនយោបាយគួរដាក់បញ្ចូលបញ្ហាចំណាកស្រុក ទៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ គឺនៅខ្វះមូលដ្ឋានជាក់ស្តែង។ គម្រោង IPPMD មានគោលដៅបំពេញកង្វះខាតចំណេះដឹងនេះ ដោយផ្តល់ភស្តុតាងគួរឲ្យទុកចិត្តពីការចូលរួមចំណែកនៃចំណាកស្រុកក្នុងការអភិវឌ្ឍ និងពីបែបបទដែលការចូលរួមនេះអាចពង្រឹងឡើងបានតាមរយៈគោលនយោបាយក្នុងវិស័យមួយចំនួន។ ក្នុងនេះ OECD បានរចនារៀបចំក្របខ័ណ្ឌគោលគំនិតមួយ ដើម្បីពិនិត្យពីចំណងទាក់ទងរវាងទិដ្ឋភាពទាំង ៤ នៃចំណាកស្រុក (ចំណាកស្រុកទៅក្រៅប្រទេស បញ្ញើមកផ្ទះ ចំណាកស្រុកត្រឡប់វិញ និងចំណាកស្រុក) ជាមួយនឹង គោលនយោបាយតាម ៥ វិស័យសំខាន់ៗគឺ ទីផ្សារពលកម្ម កសិកម្ម ការអប់រំ វិនិយោគនិងសេវាហិរញ្ញវត្ថុ និង កិច្ចការពារផ្នែកសង្គមកិច្ចនិងសុខភាព (រូបភាព១.១)។ ក្របខ័ណ្ឌគោលគំនិតនេះ ក៏តភ្ជាប់គោលនយោបាយតាម ៥ វិស័យសំខាន់ៗ ជាមួយនឹងលទ្ធផលផ្សេងៗនៃចំណាកស្រុកដែរ (តារាង១.១)។

តារាង១.១៖ ទិដ្ឋភាពនានានៃចំណាកស្រុក និង លទ្ធផលនៃចំណាកស្រុក ក្នុងការសិក្សា IPPMD

| | ទិដ្ឋភាពនៃចំណាកស្រុក | លទ្ធផលនៃចំណាកស្រុក |
|---|---|---|
| ចំណាកស្រុកចេញ | ចំណាកស្រុកចេញកើតមានឡើងនៅពេលមានមនុស្សទៅរស់នៅខាងក្រៅប្រទេសដើមរបស់ខ្លួនចាប់ពីបីខែបន្តបន្ទាប់ឡើងទៅ[i] | ការសម្រេចចិត្តធ្វើចំណាកស្រុកចេញ ជាលទ្ធផលមួយដ៏សំខាន់សម្រាប់ប្រទេសដើម ព្រោះអាចបង្កលំហូរមនុស្សចេញក្នុងរយៈពេលខ្លីផង និងបង្កើនចំនួនជនចំណាកស្រុកចេញទៅរស់នៅឯបរទេសក្នុងរយៈពេលវែងផង។ |
| បញ្ញើមកផ្ទះ | បញ្ញើមកផ្ទះ ជាការផ្ទេរអន្តរជាតិភាគច្រើនជាហិរញ្ញវត្ថុ ដែលជនចំណាកស្រុក ផ្ញើមកឲ្យអ្នកនៅឯប្រទេសដើម[ii] | ការផ្ញើ និងការទទួលបញ្ញើមកផ្ទះ រួមមាន ទឹកប្រាក់ផ្ញើមកផ្ទះទទួលបាន និងច្រកប្រើប្រាស់ដើម្បីផ្ទេរប្រាក់ដែលអាចប៉ះពាល់ដល់លទ្ធភាពធ្វើវិនិយោគក្នុងរយៈពេលវែង<br>ការប្រើប្រាស់បញ្ញើមកផ្ទះ ត្រូវបានចាត់ទុកជារឿយៗថាជាអាទិភាពមួយសម្រាប់ អ្នកកសាងគោលនយោបាយដែលតែងចង់តម្រង់វាទៅខាងវិនិយោគមានផលិតភាព។ |
| ចំណាកស្រុកត្រឡប់មកវិញ | ចំណាកស្រុកត្រឡប់មកវិញកើត មាននៅពេលជនចំណាកស្រុកទៅក្រៅប្រទេសសម្រេចចិត្តវិលត្រឡប់ និងរស់នៅ ជាបណ្តោះអាសន្ន ឬជាប់លាប់ ក្នុងប្រទេសដើមវិញ | ការសម្រេចចិត្តត្រឡប់វិញ ផុសចេញពីកត្តាផ្សេងៗ ដូចជាចំណូលចិត្តផ្ទាល់ខ្លួន និងស្ថានភាពក្នុងប្រទេសដើម។ ចំណាកស្រុកត្រឡប់មកវិញ ទោះជាបណ្តោះអាសន្ន ឬជាប់លាប់ក្តី អាចមានប្រយោជន៍ដល់ប្រទេសដើម ជាពិសេសនៅពេលពាក់ព័ន្ធនឹងអ្នកមានជំនាញខ្ពស់ៗ។<br>ចីរភាពនៃការត្រឡប់វិញ ជាខ្នាតមួយសម្រាប់វាស់វែងជោគជ័យនៃចំណាកស្រុកត្រឡប់មកវិញ ទោះបីដោយស្ម័គ្រចិត្ត ឬដោយបង្ខំក្តី សម្រាប់ជនចំណាកស្រុកនិងគ្រួសារគាត់ និងសម្រាប់ប្រទេសដើមផងដែរ។ |
| ចំណាកស្រុកចូល | ចំណាកស្រុកចូល កើតមានឡើងនៅពេលបុគ្គលម្នាក់ដែលកើតក្នុងប្រទេសមួយផ្សេង (ទោះមានសញ្ញាតិអ្វីក៏ដោយ) មកស្នាក់នៅក្នុងប្រទេសមួយទៀត បានយូរចាប់ពីបីខែឡើងទៅ | សមាហរណកម្មជនលើចំណាកស្រុកចូល មានន័យថា អ្នកទាំងនេះមានជីវភាពប្រសើរជាងមុន និងចូលរួមបានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេសដែលទទួលរូបគាត់ ហើយនិងដល់ប្រទេសដើមរបស់គាត់ផងដែរ។ |


© OECD/Cambodia Development Resource Institute 2017

វិធីសាស្ត្របង្កើតឡើងដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD និងទិន្នន័យប្រមូលបានដោយដៃគូស្រាវជ្រាវនៅតាមប្រទេសនីមួយៗ បានផ្តល់ឱកាសឲ្យបំពេញកង្វះខាតលើចំណេះដឹងស្តីពីចំណាកស្រុក និងចំណងទាក់ទងជាមួយការអភិវឌ្ឍ។ មានទិដ្ឋភាពជាច្រើនដែលធ្វើឲ្យ វិធីសាស្ត្ររបស់ IPPMD ពិសេសប្លែកខុសពីគេ និងសំខាន់សម្រាប់ជួយបំភ្លឺពីបែបបទនៃទំនាក់ទំនងចុះឡើងរវាងចំណាកស្រុក នឹងគោលនយោបាយសាធារណៈ ប៉ះពាល់ដល់ការអភិវឌ្ឍ។

- ឧបករណ៍អង្កេតដូចគ្នាត្រូវបានយកទៅប្រើក្នុងប្រទេសទាំងអស់ ក្នុងរយៈពេលដូចគ្នា (២០១៤-១៥) ដូច្នេះអាចធ្វើការប្រៀបធៀបគ្នាបានរវាងប្រទេសទាំងនោះ។
- អង្កេតបានផ្តោតលើទិដ្ឋភាពផ្សេងៗ និងលទ្ធផលនៃចំណាកស្រុក (តារាង១.១) ដូច្នេះអាចបង្ហាញបានសព្វគ្រប់ពីវដ្តនៃចំណាកស្រុក។
- គម្រោងនេះពិនិត្យលើកម្មវិធីធំទូលាយផ្នែកគោលនយោបាយរបស់ប្រទេសនានា លើ ៥ វិស័យសំខាន់ៗ។
- ការស្រាវជ្រាវបែបបរិមាណ និងបែបគុណភាព បានយកមកប្រើគួបផ្សំគ្នាដើម្បីប្រមូលទិន្នន័យបឋមយ៉ាងច្រើនលើប្រទេសដៃគូទាំង ១០។
  1) **អង្កេតគ្រួសារ** លើ ២០០០ គ្រួសារជាមធ្យម ក្នុងប្រទេសនីមួយៗ មានទាំងគ្រួសារធ្វើចំណាកស្រុក និងមិនធ្វើចំណាកស្រុក។ សរុបទាំងអស់ គម្រោងនេះបានធ្វើសម្ភាសន៍ជាង ២០.៥០០ គ្រួសារ។
  2) **អង្កេតសហគមន៍** សរុប ៥៩០ អាជ្ញាធរមូលដ្ឋាន និងអ្នកដឹកនាំសហគមន៍ ក្នុងឃុំនានាដែលមានការធ្វើសម្ភាសន៍គ្រួសារ។
  3) **សម្ភាសន៍ស៊ីជម្រៅបែបគុណភាពលើអ្នកពាក់ព័ន្ធ** បានធ្វើឡើងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដែលតំណាងឲ្យអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន មជ្ឈដ្ឋានសិក្សាអប់រំ អង្គការអន្តរជាតិ សង្គមស៊ីវិល និងវិស័យឯកជន។ សរុបមក បានធ្វើ ៣៧៦ សម្ភាសន៍ក្នុងប្រទេសទាំង ១០ ។
- ការវិភាគទិន្នន័យបានធ្វើឡើងដោយប្រើបច្ចេកទេសបែបពណ៌នា និង regression ។ បច្ចេកទេសទី១ បង្ហាញនូវលំនាំធំៗ និងទំនាក់ទំនងរវាងអថេរសំខាន់ៗនៃចំណាកស្រុក ជាមួយនឹងគោលនយោបាយសាធារណៈ រីឯបច្ចេកទេសទី២ ជួយឲ្យមានការយល់ដឹងជាក់ស្តែងកាន់តែស៊ីជម្រៅពីទំនាក់ទំនងចុះឡើងទាំងនេះ ដោយមានការត្រួតត្រាលើកត្តាផ្សេងៗទៀតផង។

មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD និង គណៈកម្មការអឺរ៉ុប បានរៀបចំក្នុងខែតុលា ២០១៦ នៅក្រុងប៉ារីស នូវកិច្ចសន្ទនាមួយស្តីពី ការទាញយកអត្ថប្រយោជន៍ពីចំណាកស្រុកតាមរយៈ គោលនយោបាយកាន់តែរលូនគ្នាល្អ។ ព្រឹត្តិការណ៍នេះបានក្លាយជាវេទិកាសម្រាប់កិច្ចសន្ទនាផ្នែកគោលនយោបាយរវាង អ្នកកសាងគោលនយោបាយនៅតាមប្រទេសដៃគូ អ្នកជំនាញផ្នែកសិក្សាស្រាវជ្រាវ សង្គមស៊ីវិល និង អង្គការពហុភាគីនានា។ ក្នុងនេះ មានការពិភាក្សាពីលទ្ធផលរកឃើញ និងគោលនយោបាយជាក់ស្តែងដែលអាចជួយបង្កើនការចូលរួមចំណែករបស់ការធ្វើចំណាកស្រុក ក្នុងការអភិវឌ្ឍទាំងក្នុងប្រទេសដើម និងប្រទេសទទួលចំណាកស្រុក។ របាយការណ៍ប្រៀបធៀបរវាងប្រទេស និងរបាយការណ៍តាមប្រទេសទាំង ១០ គ្រោងបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៧។

 © OECD/Cambodia Development Resource Institute 2017

## ហេតុអ្វីបានជាគម្រោង IPPMD បានដាក់បញ្ចូលប្រទេសកម្ពុជា?

នៅកម្ពុជា ចំណាកស្រុកទៅក្រៅប្រទេសមានច្រើនគួរឲ្យកត់សំគាល់។ តាមទិន្នន័យរបស់ អង្គការសហប្រជាជាតិ (UN) ជនចំណាកស្រុកកម្ពុជាមានប្រមាណ ១,២លាននាក់ក្នុងឆ្នាំ២០១៥ ឬ ៧,៦% នៃប្រជាជនកម្ពុជាសរុប គឺទាបជាងក្នុងប្រទេសដៃគូភាគច្រើនក្នុង IPPMD (រូបភាព១.២)។ ចំណុចគួរកត់សំគាល់ គឺក្រុមជនចំណាកស្រុកនេះបានកើនឡើងយ៉ាងលឿន។ ស្ថិតិផ្លូវការរបស់កម្ពុជាបង្ហាញថា ពីឆ្នាំ២០១០ ដល់ ២០១៥ ក្រុមជនចំណាកស្រុកបានកើនពី ០,៥ ដល់ ១,២លាននាក់ ឬកើនឡើងប្រមាណ ១៤០% (ជំពូក២)។ យោងតាមទិន្នន័យ IPPMD ដែល ប្រមាណ ១០% នៃប្រជាជនកម្ពុជាអាយុចាប់ពី ១៥ឆ្នាំឡើងទៅ មានផែនការធ្វើចំណាកស្រុក គឺជិតស្មើនឹងកម្រិតមធ្យមក្នុងចំណោមប្រទេសដៃគូនានា។

រូបភាព១.២៖ កម្ពុជាជាប្រទេសមានចំណាកស្រុកចេញសុទ្ធ

ក្រុមជនចំណាកស្រុក និងក្រុមជនចំណូលស្រុក គិតជាភាគរយនៃប្រជាជនសរុប (២០១៥)




*កំណត់សំគាល់៖ ទិន្នន័យបានមកពី ជំរឿនថ្នាក់ជាតិ អង្កេតកម្លាំងពលកម្ម និង បញ្ជីប្រជាជន*

*ប្រភព៖* UNDESA *International Migration Stock: The 2015 Revision* (database), www.un.org/en/development/desa/population/migration/data/estimates2/estimates15.shtml.

បញ្ញើមកផ្ទះ ផ្ញើឡើងដោយជនចំណាកស្រុក គឺជាប្រភពចំណូលដ៏សំខាន់សម្រាប់គ្រួសារជាច្រើននៅកម្ពុជា ហើយអាចជួយលើកស្ទួយសុខមាលភាពរបស់គ្រួសារជនចំណាកស្រុក និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ក្នុងឆ្នាំ២០១៥ លំហូរចូលបញ្ញើមកផ្ទះនៅកម្ពុជា ឡើងដល់ ៥៤២លានដុល្លារ ឬ ៣% នៃប្រាក់ចំណូលជាតិ (World Bank 2016)។ ចំពោះទំហំ និងរបៀបផ្ញើប្រាក់នេះ អាស្រ័យលើកត្តាជាច្រើន មានជាអាទិ បុគ្គលិកផ្ទាល់របស់ជនចំណាកស្រុក និង ចំណាយលើការផ្ញើ និងទទួលប្រាក់នេះ។ ការប្រៀបធៀបរវាងប្រទេសដៃគូទាំង ១០ ក្នុង IPPMD បង្ហាញថា សម្រាប់លំហូរបញ្ញើមកផ្ទះនៅកម្ពុជា ត្រូវចំណាយអស់ ១៣%នៃទឹកប្រាក់ផ្ញើ ដែលជាចំណាយកម្រិតខ្ពស់ជាងគេ (រូបភាព១.៣)។ ចំណាយនេះក៏នៅតែខ្ពស់ជខ្លាំង ធៀបនឹងកម្រិតគោលដៅ ៣%ដែលមានចែងក្នុង គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDG) (UN 2015)។

 © OECD/Cambodia Development Resource Institute 2017

រូបភាព១.៣៖ ចំណាយផ្ទេរបញ្ញើមកផ្ទះ នៅកម្ពុជា ខ្ពស់ខ្លាំង ជាងកម្រិតក្នុង SDG
ចំណាយផ្ទេរបញ្ញើមកផ្ទះ (ជា % នៃទឹកប្រាក់ផ្ញើ) ក្នុងការផ្ទេរប្រាក់ ២០០ដុល្លារ




*កំណត់សំគាល់៖ ទិន្នន័យសម្រាប់ត្រីមាសទី២ ឆ្នាំ២០១៦ ដោយដាក់ទម្ងន់តាមចំណែកនៃជនចំណាកស្រុកចេញ នៅក្នុងទិន្នន័យ IPPMD ក្នុងច្រកផ្ញើប្រាក់មកផ្ទះចម្បងៗនីមួយៗ។ ទិន្នន័យសម្រាប់ ប៊ូគីណាហ្វាសូ និង កូតឌីវ័រ មិនមានទេ។ ខ្សែបន្ទាត់តំណាងឲ្យ ចំណាយ ៣% ដែលជាគោលដៅធំទូលាយនៃរបៀបវារៈសកម្មភាព Addis Ababa ។ សម្រាប់កម្ពុជា ការគណនាចំណាយផ្អែកលើ ចំណាយផ្ទេរប្រាក់តាមច្រកផ្ញើប្រាក់មកផ្ទះ ពីថៃមកកម្ពុជា។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើ* World Bank Remittance Prices Worldwide data, http://remittanceprices.worldbank.org.

## **តើគម្រោង** IPPMD **ដំណើរការយ៉ាងដូចម្តេចនៅកម្ពុជា**?

ក្រុមអនុវត្តគម្រោង IPPMD នៅកម្ពុជា បានធ្វើការជាមួយក្រសួងមហាផ្ទៃ (MOI) ដែលដើរតួនាទីជាចំណុចស្នូលខាងផ្នែករដ្ឋាភិបាល។ ក្រសួងមហាផ្ទៃបានផ្តល់ព័ត៌មានលើអាទិភាព និងគោលនយោបាយរបស់កម្ពុជា និងជួយរៀបចំសិក្ខាសាលា និងជំនួបទ្វេភាគីផ្សេងៗនៅក្នុងប្រទេស។ ក្រុមអនុវត្តគម្រោង IPPMD ក៏បានធ្វើការជាមួយ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដើម្បីធានាឲ្យគម្រោងមានដំណើរការយ៉ាងរលូន។ CDRI បានជួយរៀបចំព្រឹត្តិការណ៍កម្រិតថ្នាក់ជាតិ ចូលរួមចំណែកក្នុងការរចនារៀបចំយុទ្ធសាស្ត្រស្រាវជ្រាវនៅកម្ពុជា ធ្វើការចុះសិក្សាដល់កន្លែង និងចងក្រងរបាយការណ៍សម្រាប់ភាគីកម្ពុជា។

ក្រុមអនុវត្តគម្រោង IPPMD បានរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាជាច្រើននៅក្នុងស្រុក ដោយមានជំនួយគាំទ្រពីគណៈប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា។ អ្នកពាក់ព័ន្ធផ្សេងៗដែលបានចូលរួមក្នុងសិក្ខាសាលា និងការជួបប្រជុំទាំងនេះ និងត្រូវបានសម្ភាសន៍ ក្នុងពេលបំពេញបេសកម្មនៅកម្ពុជាហើយ ក៏បានដើរតួនាទីក្នុងការពង្រឹងបណ្តាញនៃដៃគូនានាក្នុងគម្រោង និងកំណត់អាទិភាពស្រាវជ្រាវនៅកម្ពុជា។

នៅខែវិច្ឆិកា ២០១៣ នៅរាជធានីភ្នំពេញ មានការរៀបចំសិក្ខាសាលាមួយដើម្បីចាប់ដំណើរការគម្រោងនៅកម្ពុជា (រូបភាព១.៤) ។ សិក្ខាសាលានេះបានដើរតួនាទីជាវេទិកាមួយ សម្រាប់ការពិភាក្សាពីចំណុចផ្តោតនៃគម្រោងនៅកម្ពុជា រវាងអ្នកកសាងគោលនយោបាយថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន អ្នកតំណាងអង្គការអន្តរជាតិនានា អង្គការផ្សេងៗរបស់និយោជកនិង

 © OECD/Cambodia Development Resource Institute 2017

និយោជិត អង្គការសង្គមស៊ីវិល និង មជ្ឈដ្ឋានសិក្សាស្រាវជ្រាវ។ មានការមូលមតិគ្នាថា គម្រោងនេះគួរផ្តោតលើចំណាកស្រុកជាជាងលើចំណូលស្រុក នៅកម្ពុជា។ ក្រោយមានការពិភាក្សាយ៉ាងផុសផុលនិងសព្វគ្រប់ ក្រុមអនុវត្តគម្រោង IPPMD បានសម្រេចចិត្តផ្តោតការវិភាគលើ ៤ វិស័យ គឺ ១) ទីផ្សារពលកម្ម ២) កសិកម្ម ៣) ការអប់រំ និង ៤) វិនិយោគ និង សេវាហិរញ្ញវត្ថុ។

រូបភាព១.៤៖ តារាងពេលនៃគម្រោង IPPMD នៅកម្ពុជា




បន្ទាប់ពីក្រុមអនុវត្តគម្រោង IPPMD បានធ្វើសិក្ខាសាលាបណ្តុះបណ្តាល និងធ្វើតេស្តសាកល្បងរួចហើយ CDRI បានប្រមូលទិន្នន័យបែបបរិមាណលើ ២.០០០គ្រួសារ ក្នុង ១០០សហគមន៍ និងបានធ្វើ ២៨ បទសម្ភាសន៍លើអ្នកពាក់ព័ន្ធ (ជំពូក២)។ នៅខែមិថុនា ២០១៥ មានកិច្ចប្រជុំពិគ្រោះយោបល់មួយដើម្បីបង្ហាញ លទ្ធផលរកឃើញដំបូង ដល់ភាគីពាក់ព័ន្ធនានា រួមមាន អ្នកកសាងគោលនយោបាយ អ្នកសិក្សាស្រាវជ្រាវ និង អង្គការសង្គមស៊ីវិលនៅកម្ពុជា។ កិច្ចប្រជុំនេះបានពិភាក្សាពី ទស្សនៈនិងការបកស្រាយខុសៗគ្នាលើលទ្ធផលពីដំបូងៗ ដើម្បីបានជាទុនសម្រាប់ការវិភាគថ្នាក់ជាតិបន្ថែមទៀត។ កិច្ចសន្ទនាផ្នែកគោលនយោបាយមួយក៏បានរៀបចំឡើង ដើម្បីចែករំលែកមតិយោបល់ផ្នែកគោលនយោបាយ និងពិភាក្សាជាមួយភាគីពាក់ព័ន្ធ ពីសកម្មភាពជាក់ស្តែងផ្សេងៗ ដើម្បីទាញយកអត្ថប្រយោជន៍ឲ្យបានច្រើនបំផុតពីបញ្ហាចំណាកស្រុកសំខាន់ៗនៅកម្ពុជា។

**តើរបាយការណ៍នេះមានផ្តល់ព័ត៌មានអ្វីខ្លះពី ចំណងទាក់ទងរវាងចំណាកស្រុក និងការអភិវឌ្ឍ?**

លទ្ធផលរកឃើញមានចុះក្នុងរបាយការណ៍នេះ បង្ហាញថា ចំណាកស្រុកមានសក្តានុពលច្រើនសម្រាប់ជំរុញការអភិវឌ្ឍ ប៉ុន្តែកម្ពុជាមិនទាន់ទាញយកប្រយោជន៍បានពេញលេញទេ។ ប្រសិនបើ គោលនយោបាយតាមវិស័យផ្សេងៗបានគិតគូរពីបញ្ហាចំណាកស្រុក សក្តានុពលនេះពិតជាអាចទាញយកជាប្រយោជន៍បាន។ របាយការណ៍នេះបង្ហាញពី ទំនាក់ទំនងទៅវិញទៅមករវាងចំណាកស្រុក នឹងគោលនយោបាយសាធារណៈ តាមការវិភាគពីបែបបទដែលចំណាកស្រុកដែលអាចប៉ះពាល់ដល់វិស័យផ្សេងៗ ដូចជា ទីផ្សារពលកម្ម កសិកម្ម ការអប់រំ វិនិយោគនិងសេវាហិរញ្ញវត្ថុ ជាដើម (ជំពូក៤) នឹងត្រូវរងឥទ្ធិពលពីគោលនយោបាយក្នុងវិស័យទាំងនេះ (ជំពូក៥) ។


© OECD/Cambodia Development Resource Institute 2017

## គោលនយោបាយទីផ្សារពលកម្ម មានឥទ្ធិពលតិចតួចណាស់ដើម្បីការទប់ស្កាត់ការធ្វើចំណាកស្រុក

ការបាត់បង់កម្លាំងពលកម្មដោយសារចំណាកស្រុក អាចប៉ះពាល់ខ្លាំងដល់វិស័យខ្លះនៃសកម្មភាពសេដ្ឋកិច្ចជាពិសេស ដោយសារជនចំណាកស្រុកច្រើនស្ថិតក្នុងអាយុកំពុងមានផលិតភាពខ្ពស់បំផុតក្នុងជីវិតរបស់ខ្លួន។ តាមទិន្នន័យប្រមូលបានលើប្រទេសកម្ពុជា ជាង ៨០% នៃជនចំណាកស្រុក នាពេលបច្ចុប្បន្ន គឺមានអាយុចាប់ពី ១៥ ដល់ ៣៤ឆ្នាំ។ ច្បាស់ណាស់ វិស័យកសិកម្មកំពុងបាត់បង់កម្លាំងពលកម្មកាន់តែច្រើនឡើង ដោយសារចំណាកស្រុក បើសិនប្រៀបធៀបទៅនឹងវិស័យដទៃទៀត ដូចជា វិស័យសាងសង់ វិស័យអប់រំ ឬ សុខាភិបាល។ ចំណុចនេះក៏មានគូសបញ្ជាក់ក្នុងបទ សម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធដែរ។ ការថយចុះការផ្គត់ផ្គង់កម្លាំងពលកម្ម បានបង្កកង្វះពលករក្នុងវិស័យកសិកម្មនៅកម្ពុជា ជាពិសេសនៅតាមកសិដ្ឋានផលិតស្រូវក្នុងអំឡុងពេលប្រមូលផល។ កង្វះនេះ ក៏នាំឱ្យចំណាយផលិតកម្មកើនឡើងដែរ។

ចំណាកស្រុកបណ្តាលឲ្យ ប្រព័ន្ធកម្លាំងពលកម្មក្នុងគ្រួសារមានការផ្លាស់ប្តូរ។ សមាជិកនៃគ្រួសារមានជនចំណាកស្រុក តែងតែធ្វើការតិចជាង គ្រួសារគ្មានជនចំណាកស្រុក ហើយឥទ្ធិពលនេះមានខ្លាំងបំផុត នៅតាមគ្រួសារធ្វើកសិកម្ម។ ចំណុចនេះផ្តល់គំនិតថា ការងារដែលជនចំណាកស្រុកតែងតែធ្វើ (ភាគច្រើនជាការងារទាក់ទងនឹងកសិកម្ម) គឺគ្មានអ្នកណាធ្វើជំនួសទេ ក្នុងអំឡុងពេលពួកគេអវត្តមាន។ ការទទួលបានបញ្ញើមកផ្ទះផ្សេងៗ ក៏ជះឥទ្ធិពលអវិជ្ជមានទៅលើការសម្រេចចិត្តរបស់គ្រួសារក្នុងការផ្គត់ផ្គង់កម្លាំងពលកម្មដែរ។ ដោយឡែក ស្ត្រីតែងធ្វើការតិចជាងមុន នៅពេលគ្រួសាររបស់គាត់ទទួលបានបញ្ញើមកផ្ទះ (រូបភាព១.៥)។

រូបភាព១.៥៖ គ្រួសារទទួលបានបញ្ញើមកផ្ទះ តែងមានសមាជិកធ្វើការងារតិចនាក់ជាងមុន

ភាគរយនៃសមាជិកគ្រួសារមានអាយុពី ១៥ ដល់ ៦៤ឆ្នាំ កំពុងធ្វើការ




*កំណត់សំគាល់*៖ លទ្ធផលដែលគិតតាមកំរិតសំខាន់នៃស្ថិតិ គឺមានការបញ្ជាក់ ដូចតទៅ៖ ***: 99%, **: 95%, *: 90%


© OECD/Cambodia Development Resource Institute 2017

តើគោលនយោបាយទីផ្សារពលកម្ម ជះឥទ្ធិពលអ្វីខ្លះទៅលើចំណាកស្រុក? ការស្រាវជ្រាវរបស់ IPPMD បង្ហាញថា ស្ថាប័នរដ្ឋសម្រាប់ជួយរកការងារ ច្រើនតែព្យាយាមកាត់បន្ថយចំណាកស្រុក តាមការផ្តល់ព័ត៌មានឲ្យបាន កាន់តែប្រសើរពីទីផ្សារពលកម្មនៅកម្ពុជា។ ប៉ុន្តែអត្រានៃប្រជាជនក្នុងសំណាកដែលរកបានការងារតាមរយៈស្ថាប័នរដ្ឋ មានកម្រិតទាបត្រឹម ៤% ប៉ុណ្ណោះ។

ការបណ្តុះបណ្តាលនិងអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ជាគន្លឹះសំខាន់សម្រាប់ពង្រឹងជំនាញនៅកម្ពុជា ដូចមានចែងក្នុង គោលនយោបាយការងារថ្នាក់ជាតិឆ្នាំ២០១៥-២០២៥។ ប៉ុន្តែអង្កេតរបស់ IPPMD បង្ហាញថា មានកម្លាំងពលកម្មតែ ៥% ប៉ុណ្ណោះ ដែលធ្លាប់បានចូលរួមកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយភាគច្រើនខាងផ្នែកកសិកម្ម។ ការស្រាវជ្រាវរបស់ IPPMD រកឃើញថា ក្នុងប្រទេសខ្លះកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ហាក់ជួយឲ្យជនចំណាកស្រុកងាយរកបានការងារនៅឯបរទេស ប៉ុន្តែលទ្ធផលនៅកម្ពុជាមិនមានបង្ហាញភស្តុតាង ពីចំណងទាក់ទងរវាងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងផែនការធ្វើចំណាកស្រុកនោះទេ។

រូបភាព១.៦៖ គ្រួសារទទួលបានបញ្ញើមកផ្ទះ តែងមានសមាជិកធ្វើការងារតិចនាក់ជាងមុន

ភាគរយនៃសមាជិកគ្រួសារមានអាយុពី ១៥ ដល់ ៦៤ឆ្នាំ កំពុងធ្វើការ




កំនត់សំគាល់: សំណាកគំរូរាប់បញ្ចូល តែគ្រួសារណាដែលមានអ្នកចំណាកស្រុកត្រលប់មកវិញ

*ប្រភព*: ការគណនាផ្ទាល់របស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យ IPPMD

ម្យ៉ាងវិញទៀត កម្មវិធីផ្តល់ការងាររបស់រដ្ឋ (PEPs) (ឧទាហរណ៍ គម្រោងផ្តល់អាហារសម្រាប់ការបំពេញការងារ និងគម្រោងផ្តល់ប្រាក់សម្រាប់ការបំពេញការងារ) ហាក់ដូចមានចំណងទាក់ទងជាមួយ កំណើនចំណាកស្រុក។ នៅតាមសហគមន៍ដែលមានកម្មវិធី PEPs អត្រាមធ្យមនៃគ្រួសារមានជនចំណាកស្រុកចេញ តែងខ្ពស់ជាង នៅតាមសហគមន៍ដែលគ្មានកម្មវិធី PEPs។ ក្នុងនេះ កំណើនប្រាក់ចំណូលទទួលបានតាមរយៈ PEPs អាចជួយផ្តល់ទុនដល់ការធ្វើចំណាកស្រុករបស់សមាជិកគ្រួសារ។


© OECD/Cambodia Development Resource Institute 2017

## ឧបត្ថម្ភធនផ្នែកកសិកម្ម ជះឥទ្ធិពលដល់ការធ្វើចំណាកស្រុក

គោលនយោបាយកសិកម្ម ក៏អាចជះឥទ្ធិពលទៅលើចំណាកស្រុក និងការសម្រេចចិត្តផ្ញើបញ្ញើមកផ្ទះដែរ។ គ្រួសារជាច្រើនក្នុងសំណាក IPPMD ដែលទទួលបានអត្ថប្រយោជន៍ពីឧបត្ថម្ភធនផ្នែកកសិកម្ម ច្រើនតែមានសមាជិកគ្រោងធ្វើចំណាកស្រុក (រូបភាព១.៧)។ ចំណុចនេះផ្តល់គំនិតថា ឧបត្ថម្ភធនផ្នែកកសិកម្មជួយឲ្យមានចំណាកស្រុកចេញ តាមរយៈការផ្តល់ប្រាក់ចំណូលបន្ថែមបានច្រើនគ្រប់គ្រាន់សម្រាប់ដោះស្រាយចំណាយលើដំណើរ។ លទ្ធផលរកឃើញក៏បង្ហាញដែរថា គ្រួសារទទួលបានឧបត្ថម្ភធនផ្នែកកសិកម្ម តែងតែទទួលបានបញ្ញើមកផ្ទះ ការច្រើនជាង អ្នកមិនបានទទួលឧបត្ថម្ភធន។ ម្យ៉ាងទៀត ឧបត្ថម្ភធនដែលផ្តល់ឲ្យគ្រួសារនានានូវមធ្យោបាយដើម្បីផលិត (ឧទាហរណ៍ គ្រាប់ពូជមានគុណភាពល្អ) និងធ្វើវិនិយោគលើដីធ្លីរបស់ខ្លួន ក៏អាចជួយលើកទឹកចិត្តឲ្យជនចំណាកស្រុកផ្ញើបញ្ញើមកផ្ទះវិញ ដើម្បីបានចំណេញកាន់តែច្រើនពីវិនិយោគបែបនេះដែរ។

ការវិភាគទិន្នន័យកាន់តែស៊ីជម្រៅបង្ហាញថា ឧបត្ថម្ភធនផ្នែកកសិកម្មជះឥទ្ធិពលដល់ការធ្វើចំណាកស្រុក ដែលអាចនាំឲ្យមានបញ្ញើមកផ្ទះ។ គ្រួសារទទួលបានឧបត្ថម្ភធនផ្នែកកសិកម្ម គឺច្រើនតែមានសមាជិកធ្វើចំណាកស្រុក ហើយក៏តែងទទួលបានបញ្ញើមកផ្ទះពីសំណាក់ជនទាំងនេះដែរ។

រូបភាព១.៧៖ ឧបត្ថម្ភធនផ្នែកកសិកម្មអាចជួយបង្កើនចំណាកស្រុក និងបញ្ញើមកផ្ទះ

ភាគរយគ្រួសារទទួលបានឧបត្ថម្ភធនផ្នែកកសិកម្ម បែងចែកតាមលទ្ធផលនៃចំណាកស្រុក




*កំណត់សំគាល់*៖ លទ្ធផលដែលគិតតាមកំរិតសំខាន់នៃស្ថិតិ គឺមានការបញ្ជាក់ ដូចតទៅ៖ ***: 99%, **: 95%, *: 90%។ សម្រាប់រូបភាពខាងឆ្វេងបំផុត រាប់បញ្ចូលតែ សមាជិកគ្រួសារគ្រោងធ្វើចំណាកស្រុកក្នុង ១២ខែខាងមុខប៉ុណ្ណោះ។

*ប្រភព*: ការគណនាផ្ទាល់របស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យ IPPMD

## ផលល្អនៃការអប់រំ តែងមានកម្រិតទាបជាងអត្ថប្រយោជន៍នៃការធ្វើចំណាកស្រុក

លទ្ធផលនៃការសិក្សារបស់ IPPMD នៅកម្ពុជាបង្ហាញថា បញ្ញើមកផ្ទះជួយឲ្យគ្រួសារអាចចំណាយបានកាន់តែច្រើនទៅលើការអប់រំរបស់កូនៗ។ ប៉ុន្តែផលល្អនេះ កើតមានសម្រាប់តែគ្រួសារដែលគ្មានជនចំណាកស្រុក។ គ្រួសារមួយដែលមានសមាជិកធ្វើចំណាកស្រុក តែងមានចំណាយលើការអប់រំថយចុះ ហើយបញ្ហានេះបានលុបបំបាត់នូវផលវិជ្ជមាននៃបញ្ញើមកផ្ទះ។ វាបង្ហាញថា កុមារនៅក្នុងគ្រួសាររបស់ជនចំណាកស្រុក តែងត្រូវទទួលរ៉ាប់រងកាន់តែច្រើននូវការងារក្នុងផ្ទះ ឬក៏ទៅ


© OECD/Cambodia Development Resource Institute 2017

រកការងារនៅក្រៅផ្ទះ ដើម្បីជំនួសកម្លាំងពលកម្មរបស់ជនចំណាកស្រុក។ ការប្រមើលឃើញពីចំណាកស្រុកទៅថ្ងៃអនាគត ក៏អាចប៉ះពាល់ដល់អត្រាចុះឈ្មោះចូលរៀនដែរ។ ភស្តុតាងបន្ថែមមួយនៃស្ថានភាពនេះ គឺយុវជននិងយុវនារីដែលប្រាប់ពីចេតនានឹងធ្វើចំណាកស្រុក តែងមានអត្រាខ្ពស់ជាងក្នុងចំណោមអ្នកមិនទៅសាលារៀន (រូបភាព១.៧)។ ដំណើរបែបនេះប្រហែលជំរុញឡើង ដោយសារផលល្អនៃការអប់រំតែងមានតិចទាំងក្នុងទីផ្សារពលកម្មនៅកម្ពុជា និងនៅតាមប្រទេសជិតខាង។

រូបភាព១.៨៖ យុវជនមានផែនការធ្វើចំណាកស្រុកចេញ ទំនងមិនសូវបានទៅរៀនសាលាទេ

អត្រាយុវជន (អាយុ ១៥-២២ឆ្នាំ) ទៅរៀនសាលា គិតតាមបំណងធ្វើចំណាកស្រុកចេញ




កំណត់សំគាល់៖ លទ្ធផលមានសារៈសំខាន់ខាងស្ថិតិ គឺមានការបញ្ជាក់ ដូចតទៅ៖ ***: 99%, **: 95%, *: 90%

*ប្រភព*: ការគណនាផ្ទាល់របស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យ IPPMD

គោលនយោបាយ និងកម្មវិធីផ្នែកអប់រំនានា អាចជួយកាត់បន្ថយការធ្វើចំណាកស្រុកក្នុងបំណងរកចំណូលសម្រាប់បង់ថ្លៃសិក្សា។ គោលដៅជាយុទ្ធសាស្ត្រមួយនៃ គោលនយោបាយក្នុងវិស័យអប់រំកម្ពុជាឆ្នាំ២០១៤-២០១៨ គឺដើម្បីធានាឲ្យមានសមធម៌ក្នុងលទ្ធភាពទទួលបានការអប់រំ។ កម្មវិធីដូចជា អាហាររូបករណ៍ កម្មវិធីផ្តល់អាហារនៅសាលា និង ការចែកចាយសៀវភៅសិក្សានិងម្ហូបអាហារ តែងមានគោលដៅបង្កើនអត្រាទៅរៀនសាលា ជាពិសេស សម្រាប់កុមារក្រីក្រ និងទន់ខ្សោយ។ កម្មវិធីទាំងនេះកម្រមានជំនួយទ្រទ្រង់ជាហិរញ្ញវត្ថុណាស់ (ឧទាហរណ៍ អាហាររូបករណ៍) ហើយតែងមានដែនគ្របដណ្តប់តូច។ ការវិភាគបង្ហាញថា កម្មវិធីទាំងនេះមានឥទ្ធិពលតិចតួចណាស់ ទៅលើការសម្រេចចិត្តធ្វើចំណាកស្រុករបស់ប្រជាជន។

## ចំណាកស្រុកមិនបានជួយជំរុញវិនិយោគទេ

ទោះបីមានបញ្ញើមកផ្ទះហូរចូលយ៉ាងច្រើនមកកម្ពុជាក្តី ក៏ការស្រាវជ្រាវបង្ហាញថា ទឹកប្រាក់ទាំងនោះមិនបានយកទៅធ្វើវិនិយោគឲ្យមានផលិតភាព (ក្រៅពីក្នុងការអប់រំ) ទេ។ នេះជាការបាត់បង់ឱកាសយ៉ាងធំមួយ សម្រាប់ប្រទេសដែលកំពុងកសាងឡើងវិញនូវមូលធនភាគច្រើនរបស់ខ្លួន។ ស្រដៀងគ្នានេះដែរ ចំណាកស្រុកត្រឡប់មកវិញហាក់ដូចជាមិនបានជួយជំរុញវិនិយោគផ្សេងៗឡើយ ព្រោះគ្រួសារដែលមានជនចំណាកស្រុកត្រឡប់មកវិញ តែងចំណាយតិចលើទ្រព្យខាងកសិកម្ម និងមិនសូវមានធ្វើអាជីវកម្មទេ បើធៀបនឹងគ្រួសារគ្មានជនចំណាកស្រុកត្រឡប់មកវិញ។ គោលនយោបាយសម្រាប់ជួយគាំទ្រ និងសម្រួលឲ្យគ្រួសារបង្វែរបញ្ញើមកផ្ទះទៅរកការប្រើប្រាស់មានផលិតភាព និងវិធានការជំរុញការធ្វើវិនិយោគរបស់ជនចំណាកស្រុកត្រឡប់វិញ មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់សាមីគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់ការអភិវឌ្ឍប្រទេសជាតិទៀតផង។


© OECD/Cambodia Development Resource Institute 2017

តើគោលនយោបាយតាមវិស័យផ្សេងៗ អាចពន្យល់ពី អត្រាវិនិយោគទាបនៃបញ្ញើមកផ្ទះឬទេ? ការដាក់បញ្ចូលផ្នែកហិរញ្ញវត្ថុ (ឧទាហរណ៍ ការមានគណនីនៅធនាគារ) សំខាន់ជាខ្លាំងក្នុងការតម្រង់ទិសបញ្ញើមកផ្ទះ ទៅខាងវិនិយោគមានផលិតភាព ហើយវាក៏ជះឥទ្ធិពលទៅលើទឹកប្រាក់នៃបញ្ញើមកផ្ទះ និងជួយជំរុញការផ្ទេរប្រាក់តាមរយៈបណ្តាញផ្លូវការដែរ។ ប៉ុន្តែសព្វថ្ងៃ ការប្រើប្រាស់គណនីធនាគារនៅមានកម្រិតទាបនៅកម្ពុជា ហើយអ្នកទទួលបញ្ញើមកផ្ទះជាច្រើននាក់ ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត មិនមានគណនីនៅធនាគារទេ។ ម្យ៉ាងទៀត ការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុនៅមានកម្រិតទាបណាស់ ទាំងក្នុងចំណោមគ្រួសារមានជនចំណាកស្រុក និងគ្រួសារគ្មានជនចំណាកស្រុក ទោះបីអង្គការមិនមែនរដ្ឋាភិបាលនានា និងរដ្ឋាភិបាល បានផ្តួចផ្តើមគំនិតអនុវត្តវាក្តី។ បច្ចុប្បន្ននៅមានមធ្យោបាយសម្រាប់ ពង្រីកលទ្ធភាពបានប្រើប្រាស់គណនីធនាគារ និងកម្មវិធីបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុ ដើម្បីលើកទឹកចិត្តឲ្យមានការផ្ញើបញ្ញើមកផ្ទះកាន់តែច្រើនតាមរយៈបណ្តាញផ្លូវការ និងសម្រួលឲ្យគ្រួសារនានាអាចធ្វើវិនិយោគមានផលិតភាពច្រើន។

## របៀបវារៈគោលនយោបាយកាន់តែរលូនគ្នា ញាំងឲ្យចំណាកស្រុកអាចជួយជំរុញដល់ការអភិវឌ្ឍ

របាយការណ៍នេះរកឃើញថា ចំណាកស្រុក ឆ្លងតាមទិដ្ឋភាពផ្សេងៗ ដូចជា ចំណាកស្រុកចេញ បញ្ញើមកផ្ទះ និងចំណាកស្រុកត្រឡប់មកវិញ ដូចមានវិភាគក្នុងការសិក្សា IPPMD នេះ អាចជួយរួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។ ប៉ុន្តែសក្តានុពលក្នុងការអភិវឌ្ឍនេះ ហាក់ដូចមិនទាន់សម្រេចបានពេញលេញទេ។ របាយការណ៍នេះផ្តល់ការបំភ្លឺមួយចំនួនពី បែបបទអាចទាញយកប្រយោជន៍បានកាន់តែប្រសើរពីសក្តានុពលនេះ តាមការពិនិត្យពីឥទ្ធិពលដោយចេតនា ឬអចេតនានៃគោលនយោបាយតាមវិស័យផ្សេងៗ (ជាពិសេស គោលនយោបាយគ្រប់គ្រង ទីផ្សារពលកម្មកសិកម្ម ការអប់រំ វិនិយោគនិងសេវាហិរញ្ញវត្ថុ) ក្នុងការសម្រេចចិត្តរបស់ប្រជាជនដើម្បីធ្វើចំណាកស្រុកចេញ ឬចំណាកត្រឡប់មកវិញ និងក្នុងបែបបទដែលពួកគេផ្ញើ និងប្រើប្រាស់បញ្ញើមកផ្ទះ។

លទ្ធផលរកឃើញទាំងនេះបង្ហាញថា ដើម្បីគ្រប់គ្រងលើផលប៉ះពាល់នៃចំណាកស្រុកទៅលើការអភិវឌ្ឍ ប្រទេសនីមួយៗត្រូវមានក្របខ័ណ្ឌគោលនយោបាយរលូនគ្នាល្អ។ កម្ពុជាបានចាប់ផ្តើមអនុម័តនាពេលថ្មីៗនូវ គោលនយោបាយស្តីពីចំណាកស្រុក។ គោលនយោបាយស្តីពីការគ្រប់គ្រងលើចំណាកស្រុកនៃកម្លាំងពលកម្ម សំដៅកែលំអការគ្រប់គ្រងសេវាផ្តល់ការងារ និងការពារពលករកម្ពុជានៅឯបរទេស (MOLVT 2015)។ ប៉ុន្តែបណ្តាក្រសួងទទួលបន្ទុកលើវិស័យផ្សេងៗជារឿយៗបានមើលរំលងផលប៉ះពាល់នៃចំណាកស្រុកទៅលើវិស័យរៀងៗខ្លួន ក៏ដូចជា ឥទ្ធិពលនៃគោលនយោបាយរបស់ក្រសួងទៅលើចំណាកស្រុក។ របាយការណ៍នេះស្នើឲ្យគិតគូរពីចំណាកស្រុក នៅពេលរចនារៀបចំគោលនយោបាយសម្រាប់វិស័យផ្សេងៗ និង រៀបចំផែនការអភិវឌ្ឍន៍កម្រិតជាតិសម្រាប់ប្រទេសកម្ពុជា។

ផ្នែកខាងក្រោមនេះមានផ្តល់មតិពី គោលនយោបាយសម្រាប់វិស័យនីមួយៗដែលបានសិក្សាក្នុងគម្រោង IPPMD នៅកម្ពុជា។ ការផ្តល់មតិផ្នែកគោលនយោបាយតាមវិស័យខុសៗគ្នា និង ទិដ្ឋភាពផ្សេងៗនៃចំណាកស្រុកដែលផុសចេញពីការសិក្សាក្នុងប្រទេសទាំង ១០ មានចុះនៅក្នុងរបាយការណ៍ប្រៀបធៀប IPPMD (OECD 2017) ។

## ការដាក់បញ្ចូលបញ្ហាចំណាកស្រុកនិងការអភិវឌ្ឍ ទៅក្នុងគោលនយោបាយលើទីផ្សារពលកម្ម

ដោយសារចំណាកស្រុកចេញ ទីផ្សារពលកម្មកម្ពុជាកំពុងបាត់បង់ពលករមិនសូវមានជំនាញ ជាពិសេសក្នុងវិស័យកសិកម្ម។ វិស័យនេះប្រឈមមុខនឹងកង្វះកម្លាំងពលកម្ម ជាពិសេសនៅតាមតំបន់ជនបទ។ ឱកាសការងារល្អប្រសើរជាង និងប្រាក់កម្រៃខ្ពស់ជាងនៅឯបរទេស បានទាក់ទាញពលករជាច្រើនដែលមានជំនាញសមស្រប។ អង្កេត IPPMD បានរកឃើញថា ស្ថាប័នរដ្ឋជួយរកការងារ និង កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ មានផលប៉ះពាល់តិចតួចទៅលើការ

សម្រេចចិត្តធ្វើចំណាកស្រុក ហើយភាគច្រើនប្រហែលដោយសារអត្រារកការងារបាន ធ្វើតាមនោះមានកម្រិតទាប រីឯដែនគ្រប់ដណ្តប់ក៏មានត្រឹមតែតំបន់ខ្លះៗ។

- ត្រូវពង្រីកសកម្មភាពស្ថាប័នជួយរកការងារ ដើម្បីឲ្យដល់ជនចំណាកស្រុកចេញកំពុងស្ថិតនៅឯបរទេស និងជនចំណាកស្រុកត្រឡប់មកដល់ផ្ទះវិញ ដើម្បីធានាឲ្យពួកគេទទួលបានព័ត៌មាន និងអាចទទួលបានការងារមានប្រាក់កម្រៃជាផ្លូវការ។ ទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងស្ថាប័នជួយរកការងារ នឹងវិស័យឯកជន សំខាន់ជាខ្លាំងដើម្បីសម្រេចកិច្ចការនេះ។
- កែលំអកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឲ្យវាកាន់តែចំគោលដៅ និងអាចបន្សុីតម្រូវការជាមួយនឹងការផ្គត់ផ្គង់បាន។ ក្នុងនេះ ការធ្វើផែនទីនៃកង្វះកម្លាំងពលកម្ម និងការពង្រឹងយន្តការសម្របសម្រួលជាមួយវិស័យឯកជន គឺជាជំហានដ៏សំខាន់។ កម្មវិធីបណ្តុះបណ្តាលក៏សំដៅជួយសម្រួលឲ្យជន ចំណាកស្រុកត្រឡប់មកវិញ បានចូលទៅក្នុងទីផ្សារពលកម្មដែរ។

**ការទាញយកប្រយោជន៍ឲ្យបានច្រើនបំផុតពីចំណាកស្រុក ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម**

ដោយសារកសិកម្មបន្តដើរតួនាទីយ៉ាងសំខាន់នៅកម្ពុជា ដូច្នេះជាការសំខាន់បំផុតដែលកម្ពុជាត្រូវបង្កើតយន្តការដើម្បីទាញយកប្រយោជន៍ឲ្យបានច្រើនជាអតិបរមាពីចំណាកស្រុក ដើម្បីជំរុញការអភិវឌ្ឍវិស័យនេះ។ ប៉ុន្តែការវិភាគផ្អែកលើទិន្នន័យ IPPMD បង្ហាញថា ចំណាកស្រុកមានឥទ្ធិពលតិចតួចទៅលើវិស័យកសិកម្មនៅកម្ពុជា។ ចំណាកស្រុកចេញមិនបានផ្លាស់ប្តូរការប្រើប្រាស់កម្លាំងពលកម្មកសិកម្មក្នុងគ្រួសារ នៅក្នុងគ្រួសារដែលមានជនចំណាកស្រុកចេញនោះទេ។ ជាក់ស្តែង គ្រួសារមានជនចំណាកស្រុកចេញ តែងមានជួលប្រើកម្លាំងពលកម្មកសិកម្មពីខាងក្រៅ តិចជាង គ្រួសារគ្មានជនចំណាកស្រុកចេញ។ ស្ថានភាពនេះអាចជាការបាត់បង់ឱកាសមួយ ដើម្បីញ៉ាំងឲ្យទីផ្សារពលកម្មក្នុងវិស័យនេះរស់រវើកឡើងវិញ។ ចំណាកស្រុកមិនបាននាំមកនូវ ការធ្វើវិនិយោគក្នុងវិស័យកសិកម្មទេ។ បញ្ញើមកផ្ទះ និងចំណាកស្រុកត្រឡប់វិញមិនមែនជា កត្តានាំឲ្យមានការធ្វើវិនិយោគលើទ្រព្យសម្បត្តិ និងការធ្វើពិពិធកម្មក្នុងវិស័យកសិកម្ម ឬក៏ ការធ្វើវិនិយោគក្នុងអាជីវកម្មមិនមែនកសិកម្មនោះទេ។ នេះជាបញ្ហាមួយគួរឲ្យកត់សំគាល់ ព្រោះរដ្ឋាភិបាលបានដាក់វិស័យកសិកម្មជាវិស័យចំបង និងជាចំណុចស្នូល នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន។ គោលនយោបាយបានអនុម័តចេញ ជាពិសេសទាក់ទងនឹងឧបត្ថម្ភធនផ្នែកកសិកម្ម ក៏ជះឥទ្ធិពលទៅលើចំណាកស្រុកដែរ។ គ្រួសារទទួលបានអត្ថប្រយោជន៍ពីឧបត្ថម្ភធនផ្នែកកសិកម្ម ច្រើនតែ មានសមាជិកម្នាក់គ្រោងធ្វើចំណាកស្រុកចេញ មានសមាជិកម្នាក់ធ្លាប់ធ្វើចំណាកស្រុកចេញ និងធ្លាប់ទទួលបានបញ្ញើមកផ្ទះទៀតផង។ ស្ថានភាពនេះមានផលពាក់ព័ន្ធដល់ គោលនយោបាយសំដៅ:

- ធានាឲ្យ គ្រួសារធ្វើកសិកម្មអាចទទួលបានកម្លាំងពលកម្មកសិកម្ម នៅពេលមានតម្រូវការ។ ដែនគ្រប ដណ្តប់កាន់តែធំនៅតំបន់ជនបទរបស់ស្ថាប័នទីផ្សារពលកម្មនានា អាចជួយឲ្យគ្រួសារធ្វើកសិកម្ម រកបានអ្នកមកជំនួសកម្លាំងពលកម្មដែលបាត់បង់ទៅដោយសារចំណាកស្រុកចេញ។ បើសិនគ្មានស្ថាប័នបែបនេះទេ វិស័យកសិកម្មសន្តិសុខស្បៀង និងភាពក្រីក្រ អាចយ៉ាប់យ៉ឺនថែមទៀត នៅតាមតំបន់ដែលបានអត្រាចំណាកស្រុកចេញខ្ពស់។
- ផ្តល់ភាពងាយស្រួលដល់ លំហូរនៃបញ្ញើមកផ្ទះទៅខាងវិនិយោគផលិតភាព ដូចជាតាមរយៈការធានាថាប្រតិបត្តិករផ្ទេរប្រាក់មានធ្វើសកម្មភាពនិងមានតម្លៃសមរម្យនៅតាមតំបន់ជនបទ គ្រួសារនានាមានការបណ្តុះបណ្តាលផ្នែកវិនិយោគនិងមានជំនាញផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ ហើយហេដ្ឋារចនាសម្ព័ន្ធក៏មានជាស្រេច។ ការរាំងស្ទះធ្វើឲ្យថយចុះវិនិយោគក្នុងវិស័យកសិកម្ម គឺជា ការខាតបង់ឱកាសប្រើប្រាស់សក្តានុពលនៃបញ្ញើមកផ្ទះនិង


© OECD/Cambodia Development Resource Institute 2017

ចំណាកស្រុកត្រឡប់មកវិញ ដើម្បីជំរុញការអភិវឌ្ឍក្នុងវិស័យនេះ។ ម្យ៉ាងទៀត ឧបសគ្គផ្នែកសេដ្ឋកិច្ច និងរដ្ឋបាល ដូចជា ចំណាយខ្ពស់លើការផ្ញើបញ្ញើ និងកង្វះខាតកម្មវិធីជួយឲ្យជនចំណាកស្រុកត្រឡប់មកវិញបានចូលមករួមរស់ជាថ្មីក្នុងសង្គម ក៏អាចកាត់បន្ថយសក្តានុពលនៃកត្តាទាំងនេះដែរ។

- ចងភ្ជាប់ជំនួយទ្រទ្រង់ផ្នែកកសិកម្មជាមួយនឹងលទ្ធផលក្រោយការអនុវត្ត ជាជាងផ្តល់ជំនួយឲ្យជាមុន។ ការវិភាគលើឧបត្ថម្ភធនផ្នែកកសិកម្មនៅកម្ពុជាបង្ហាញថា កម្មវិធីនានាដែលគ្មានការចងភ្ជាប់ក្នុងកម្រិតណាមួយទៅនឹងលទ្ធផល ឬក៏គ្មានផ្តល់នូវទ្រព្យសកម្មមិនអាចដោះដូរបាន (ឧទាហរណ៍ ដីធ្លី) អាចជួយជំរុញឲ្យមានចំណាកស្រុកចេញកាន់តែច្រើនថែមទៀត។ ស្ថានភាពបែបនេះ អាចផ្ទុយពីគោលដៅនៃកម្មវិធី ប្រសិនបើវាសំដៅតែរក្សាទុកកសិករនៅក្នុងប្រទេស និងក្នុងវិស័យកសិកម្មនោះ។ ក្នុងពេលជាមួយគ្នា ការចងភ្ជាប់ឧបត្ថម្ភធនទៅនឹងលទ្ធផលមិនគួរបង្កឧបសគ្គដល់ការពិតជាក់ស្តែងដែលថា ឧបត្ថម្ភធន អាចជួយបង្កើនបញ្ញើមកផ្ទះ និងបានជាប្រយោជន៍ដល់គ្រួសារនានានោះទេ។

## ការពង្រឹងចំណងទាក់ទងរវាងចំណាកស្រុក និងវិនិយោគក្នុងវិស័យអប់រំ

លទ្ធផលរកឃើញតាមគម្រោង IPPMD បង្ហាញពី ចំណងទាក់ទងសំខាន់ៗជាច្រើនរវាងចំណាកស្រុក នឹងការអប់រំនៅកម្ពុជា។ គ្រួសារទទួលបានបញ្ញើមកផ្ទះ តែងមានចំណាយលើការអប់រំ ច្រើនជាង គ្រួសារមិនបានទទួលបញ្ញើ ដូច្នេះ បញ្ញើជួយជំរុញវិនិយោគលើធនធានមនុស្ស។ លទ្ធផលក៏បង្ហាញដែរថា អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាមានកម្រិតខ្ពស់ជាងគេក្នុងចំណោម ក្មេងប្រុសក្នុងគ្រួសារមានជនចំណាកស្រុកចេញនៅជនបទ។ បញ្ហានេះអាចជំរុញឡើងមួយភាគ ដោយសារបំណងធ្វើចំណាកស្រុកចេញទៅធ្វើការងារមានជំនាញទាបនៅក្រៅប្រទេស បានកាត់បន្ថយទឹកចិត្តចង់ចូលរៀនថ្នាក់ឧត្តមសិក្សា។ ឥទ្ធិពលវិជ្ជមាននៃបញ្ញើមកផ្ទះទៅលើការវិនិយោគខាងផ្នែកអប់រំ គួរមានគួបផ្សំគ្នាដែរ ជាមួយនឹងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្នែកអប់រំ ដើម្បីធានាឲ្យប្រជាជនទទួលបានការអប់រំប្រកបដោយគុណភាព។ សំខាន់ដូចគ្នាដែរ ត្រូវធានាឲ្យយុវជន ជាពិសេសនៅតាមតំបន់ជនបទដែលមានអត្រាចំណាកស្រុកចេញកម្រិតខ្ពស់ មានមធ្យោបាយ និងទឹកចិត្ត ដើម្បីបញ្ចប់បានពេញលេញនូវវដ្តដ៏ចាំបាច់នៃការអប់រំនៅកម្ពុជា។

គោលនយោបាយអប់រំហាក់មិនសូវមានឥទ្ធិពលច្រើនទេទៅលើ ការសម្រេចចិត្តធ្វើចំណាកស្រុករបស់គ្រួសារ។ លទ្ធផលរកឃើញបង្ហាញពីចំណងទាក់ទងវិជ្ជមាន រវាងការទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយផ្នែកអប់រំ នឹងការទទួលបញ្ញើមកផ្ទះ ប៉ុន្តែគោលនយោបាយនេះ ហាក់ដូចមិនមានឥទ្ធិពលទៅលើការសម្រេចចិត្តធ្វើចំណាកស្រុកចេញនោះទេ។ ហេតុផលមួយនៃចំណងទាក់ទងខ្សោយនេះ អាចមកពីកម្មវិធីនានាពឹងផ្អែកខ្លាំងលើជំនួយទ្រទ្រង់មិនមែនជាប្រាក់ កាក់ និងគ្របដណ្តប់បានតិចតំបន់ណាស់។

- បង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្នែកអប់រំ ដើម្បីឆ្លើយតបនឹង កំណើនតម្រូវការនូវការអប់រំដោយសារមានបញ្ញើមកផ្ទះ ដើម្បីឲ្យប្រជាជនអាចទទួលបានការអប់រំប្រកបដោយគុណភាព។
- ពង្រីកកម្មវិធីចែកចាយសាច់ប្រាក់និងសម្ភារៈ នៅតាមតំបន់មានចំណាកស្រុកចេញកម្រិតខ្ពស់ ដើម្បីឲ្យយុវជនមានមធ្យោបាយរៀនចប់មធ្យមសិក្សា។

 © OECD/Cambodia Development Resource Institute 2017

### ការពង្រឹងចំណងទាក់ទងរវាងចំណាកស្រុកការវិនិយោគ សេវាហិរញ្ញវត្ថុ នឹងការអភិវឌ្ឍ

ការស្រាវជ្រាវនេះបានរកឃើញថា បញ្ញើមកផ្ទះមានមានទំនាក់ទំនងអវិជ្ជមាន ជាមួយនឹងកម្មសិទ្ធិលើអាជីវកម្ម។ គ្រួសារទទួលបានប្រាក់បញ្ញើ ពុំសូវឃើញមានប្រកបរបរអាជីវកម្មទេ។

លទ្ធផលរកឃើញក្នុងគម្រោង IPPMD បង្ហាញពីទំនាក់ទំនងតិចតួចពេក ឬក៏អវិជ្ជមានផង រវាងបញ្ញើមកផ្ទះ ចំណាកស្រុកត្រឡប់វិញ នឹងវិនិយោគ។ បញ្ញើមកផ្ទះគ្មានចំណងទាក់ទង ទោះវិជ្ជមានឬអវិជ្ជមានក្តី ជាមួយនឹង អាជីវកម្ម ឬ កម្មសិទ្ធិលើអចលនទ្រព្យនោះទេ។ ក្នុងបរិបទដែលចំណាកស្រុកច្រើនតែជាយុទ្ធសាស្ត្រដោះទាល់ក្នុងជីវភាពរស់នៅ បញ្ញើមកផ្ទះភាគច្រើនណាស់តែងយកទៅប្រើសម្រាប់ទិញស្បៀងអាហារ ថែទាំសុខភាព និងសងបំណុល ហើយវាអាចមិនធំគ្រប់គ្រាន់សម្រាប់ធ្វើវិនិយោគមានផលិតភាពនោះទេ។ ការទទួលបានបញ្ញើមកផ្ទះ ក៏មិនជាប់ទាក់ទងនឹង ការធ្វើវិនិយោគទៅលើទ្រព្យផលិតកម្ម ដូចជា ដីមិនមែនសម្រាប់កសិកម្ម ឬ អចលនទ្រព្យ នោះដែរ។ គេរកឃើញទៀតថា ចំណាកស្រុកត្រឡប់មកវិញមានទំនាក់ទំនងអវិជ្ជមានជាមួយនឹង កម្មសិទ្ធិលើអាជីវកម្ម។

មួយវិញទៀត ការមានគណនីនៅធនាគារ ហាក់ដូចមានឥទ្ធិពលវិជ្ជមានទៅលើ លំនាំនៃបញ្ញើមកផ្ទះ។ ក្រៅពីការសម្រួលឲ្យបញ្ញើមកផ្ទះអាចមានទឹកប្រាក់កាន់តែច្រើន ការប្រើប្រាស់គណនីនៅធនាគារក៏ជួយកាត់បន្ថយការផ្ទេរប្រាក់តាមរយៈបណ្តាញក្រៅផ្លូវការដែរ។ ប៉ុន្តែការប្រើប្រាស់គណនីនៅធនាគារមានកម្រិតទាបណាស់នៅកម្ពុជា ហើយអ្នកទទួលបញ្ញើជាច្រើននាក់ ទាំងនៅពេលបច្ចុប្បន្ន និងទៅអនាគត មិនមានលទ្ធភាពប្រើប្រាស់ គណនីនៅធនាគារជាផ្លូវការនោះទេ។ គោលនយោបាយដើម្បីបង្កើនលទ្ធភាពបានប្រើប្រាស់គណនីនៅធនាគារអាចជួយជំរុញការផ្ញើបញ្ញើមកផ្ទះ និងសម្រួលឲ្យវាហូរឆ្លងកាត់តាមស្ថាប័នហិរញ្ញវត្ថុផ្លូវការ។

- លើកស្ទួយសហគ្រិនភាពឆ្លងតាម ដំណាក់កាលផ្សេងៗនៃការអភិវឌ្ឍន៍ ដូចជាការបង្កើតនិងគ្រប់គ្រងអាជីវកម្ម ជួយឲ្យជនចំណាកស្រុកត្រឡប់វិញ និងគ្រួសារទទួលបញ្ញើមកផ្ទះ ចេះជំនះលើឧបសគ្គរារាំងលើការវិនិយោគ។ ជំរុញការធ្វើវិនិយោគបញ្ញើមកផ្ទះ ឲ្យវាកាន់តែមានផលិតភាព។
- អនុវត្តកម្មវិធីអប់រំផ្នែកហិរញ្ញវត្ថុថ្នាក់ជាតិ ដើម្បីបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជាទូទៅ ជនចំណាកស្រុក និងជាពិសេស គ្រួសាររបស់ពួកគេ ដើម្បីជំរុញការហូរចូល បញ្ញើមកផ្ទះឲ្យបានកាន់តែច្រើន ទៅខាងវិនិយោគមានផលិតភាព។
- កាត់បន្ថយចំនួនប្រជាជនកម្ពុជាដែលគ្មានគណនីនៅធនាគារ ដោយពង្រីកវត្តមានរបស់ស្ថាប័ន ហិរញ្ញវត្ថុ និងការផ្តល់សេវាហិរញ្ញវត្ថុ ឲ្យរីកហួសពីទីក្រុងនិងតំបន់មានការអភិវឌ្ឍច្រើន ដើម្បីជំរុញ ការផ្ញើបញ្ញើមកផ្ទះតាមច្រកផ្លូវការ។

## ប្លង់របាយការណ៍

ជំពូកបន្ទាប់នេះពិភាក្សាពី បែបបទដែលចំណាកស្រុកបានវិវត្តនៅកម្ពុជា និងពិនិត្យពីការស្រាវជ្រាវដែលមានស្រាប់លើទំនាក់ទំនងរវាងចំណាកស្រុក នឹងការអភិវឌ្ឍ។ ក្នុងនោះក៏មានការពណ៌នាដោយសង្ខេបពី បរិបទនៃគោលនយោបាយបច្ចុប្បន្ន និងក្របខ័ណ្ឌច្បាប់ស្តីពីចំណាកស្រុកដែរ។ ជំពូក៣ មានពន្យល់ពី ការចុះប្រមូលទិន្នន័យ និង វិធីសាស្ត្រវិភាគបានយកមកប្រើសម្រាប់ធ្វើការស្រាវជ្រាវតាមបទពិសោធន៍ជាក់ស្តែង។ ក្នុងនោះក៏មានការបង្ហាញពី លទ្ធផលដែលអង្កេត IPPMD បានរកឃើញទាក់ទងនឹង ចំណាកស្រុកចេញ បញ្ញើមកផ្ទះ និងចំណាកស្រុកត្រឡប់មកវិញដែរ។ ជំពូក៤


© OECD/Cambodia Development Resource Institute 2017

ពិភាក្សាពី បែបបទដែលទិដ្ឋភាពទាំងបីនៃចំណាកស្រុក ជះឥទ្ធិពលទៅលើ ៤ វិស័យសំខាន់ៗនៅកម្ពុជា៖ ទីផ្សារពលកម្ម កសិកម្ម ការអប់រំនិងវិនិយោគ និងសេវាហិរញ្ញវត្ថុ។ ជំពូក៥ មានបង្ហាញពីបែបបទដែលគោលនយោបាយក្នុងវិស័យទាំងនេះ ជះឥទ្ធិពលទៅលើលទ្ធផលចំណាកស្រុក។

**កំណត់សំគាល់**

១ ដោយសារកង្វះទិន្នន័យ តួនាទីនៃជនចំណាកស្រុកចេញយូរឆ្នាំ (diasporas) ដែលជារឿយៗចូលរួមសកម្មក្នុងសមាគមបណ្តាញវិជ្ជាជីវៈ និងផលប្រយោជន៍ផ្សេងៗក្នុងប្រទេសដើម មិនមានពិនិត្យវិភាគទេក្នុងរបាយការណ៍នេះ។

២ ក្រៅពីការផ្ទេរហិរញ្ញវត្ថុ ជាលក្ខណៈប្រាក់បញ្ញើមកផ្ទះ ក៏មាន បញ្ញើបែបសង្គម ដូចជា គំនិត តម្លៃសីលធម៌ មូលធនសង្គម ដែលជនចំណាកស្រុកផ្ទេរមកដែរ។ បញ្ញើបែបសង្គម ជាទិដ្ឋភាពដ៏សំខាន់មួយនៃទំនាក់ទំនង ចំណាកស្រុក-អភិវឌ្ឍន៍ ក៏ពិតមែន ប៉ុន្តែវាធំហួសដែនកំណត់នៃគម្រោងនេះ ដូច្នេះមិនមានលើកមកពិភាក្សាក្នុងរបាយការណ៍នេះទេ។

---

[i] ដោយសារកង្វះទិន្នន័យ តួនាទីនៃជនចំណាកស្រុកចេញយូរឆ្នាំ (diasporas) ដែលជារឿយៗចូលរួមសកម្មក្នុងសមាគមបណ្តាញវិជ្ជាជីវៈ និងផលប្រយោជន៍ផ្សេងៗក្នុងប្រទេសដើម មិនមានពិនិត្យវិភាគក្នុងរបាយការណ៍នេះទេ។

[ii] ក្រៅពីការផ្ទេរហិរញ្ញវត្ថុ ជាលក្ខណៈប្រាក់បញ្ញើមកផ្ទះ ក៏មាន បញ្ញើបែបសង្គម ដូចជា គំនិត តម្លៃសីលធម៌ មូលធនសង្គម ដែលជនចំណាកស្រុកផ្ទេរមកដែរ។ បញ្ញើបែបសង្គម ជាទិដ្ឋភាពដ៏សំខាន់មួយនៃទំនាក់ទំនង ចំណាកស្រុក-ការអភិវឌ្ឍ ក៏ពិតមែន ប៉ុន្តែវាធំហួសដែនកំណត់នៃគម្រោងនេះ ដូច្នេះមិនមានលើកមកពិភាក្សាក្នុងរបាយការណ៍នេះទេ។


© OECD/Cambodia Development Resource Institute 2017

OECD Development Pathways

# Interrelations between Public Policies, Migration and Development in Cambodia

This project is co-funded by
the European Union